ភ្នំពេញ ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦

# សេចក្តីប្រកាសព័ត៌មាន
# ការប្រឆាំងអំពើពុករលួយកំពុងក្លាយជាគោលនយោបាយចំបង

អង្គការតម្លាភាពកម្ពុជារៀបចំដំណើរការដាក់ជូនសេចក្តីស្នើគោលនយោបាយប្រឆាំងអំពើពុករលួយទៅគណបក្សនយោបាយ។

សេចក្តីស្នើរគោលនយោបាយនេះ បានរួមបញ្ចូលលទ្ធផលនៃកិច្ចពិគ្រោះយោបល់ទាំងបីលើក ដោយមានការចូលរួមពីអង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍/សហគមន៍អ្នកផ្តល់ជំនួយ ក៏ដូចជាគណបក្សនយោបាយ។ ក្នុងកិច្ចពិគ្រោះយោបល់ទាំងនោះ អ្នកចូលរួមបានផ្លាស់ប្តូរទស្សនៈលើច្បាប់សំខាន់ៗដើម្បីប្រឆាំងអំពើ ពុករលួយ សមត្ថភាពស្ថាប័ននៃភ្នាក់ងារអនុវត្តច្បាប់ និងការចូលរួមពីសហគមន៍ក្នុងការប្រឆាំងអំពើពុករលួយ។

ការទាមទារពីសាធារណៈជនក្នុងការលុបបំបាត់អំពើពុករលួយបានកើនឡើងដល់កម្រិតខ្ពស់បំផុត ពុំធ្លាប់មានពីមុនមក ជាពិសេសក្នុងចំណោមអ្នកបោះឆ្នោតវ័យក្មេង ដែលមានចំនួនកើនឡើងជាលំដាប់ ដែលពួកគេមើលឃើញថា អំពើពុករលួយជាឧបសគ្គធំបំផុតដែលរារាំងការអភិវឌ្ឍជាតិ ដូច្នេះទើបពួកគេមានជំហរយ៉ាងរឹងមាំក្នុងការប្រឆាំងអំពើពុករលួយ។ យោងតាមការស្ទង់មតិថ្នាក់ជាតិស្តីពី «សុចរិតភាពយុវជន» គឺមានយុវជនរហូតដល់ទៅ ៩៩% ដែលគិតថា អំពើពុករលួយជាបញ្ហាចំបងបំផុត ដែលរារាំងការអភិវឌ្ឍរបស់ប្រទេសកម្ពុជា។ អង្គការតម្លាភាពកម្ពុជា ជឿជាក់ថា សេចក្តីស្នើគោលនយោបាយប្រឆាំងអំពើពុករលួយនេះ នឹងផ្តល់ឱកាសឲ្យមានការទាក់ទាញចំណាប់អារម្មណ៍ និងការវាយតម្លៃអំពីឆន្ទៈរបស់ថ្នាក់ដឹកនាំគណបក្សនយោបាយក្នុងការប្រឆាំងអំពើពុករលួយ។

លោក **ព្រាប កុល** នាយកប្រតិបត្តិអង្គការតម្លាភាពកម្ពុជា បានមានប្រសាសន៍៖ «ខ្ញុំជឿជាក់ថាគ្រប់គណបក្សនយោបាយដែលប្រកួតប្រជែងក្នុងការបោះឆ្នោត នឹងត្រូវតែជជែកអំពីបញ្ហាពុករលួយ និងប្រាប់ពីវិធីប្រឆាំងអំពើពុករលួយ ប្រសិនបើគណបក្សទាំងនោះចង់បានការគាំទ្រពីអ្នកបោះឆ្នោតភាគច្រើន។ ដូច្នេះ សេចក្តីស្នើគោលនយោបាយប្រឆាំងអំពើពុករលួយ ត្រូវបានបង្កើតឡើងក្នុងគោលបំនងទាក់ទាញចំណាប់ អារម្មណ៍ និងនាំអ្នកនយោបាយឆ្ពោះទៅរកវិធានការចំបងៗ ដែលយើងជឿថាជាគន្លឹះក្នុងការប្រឆាំងអំពើពុករលួយ ឲ្យកាន់តែមានប្រសិទ្ធភាព»។ លោកបានបន្ថែមថា៖ «អ្វីដែលសំខាន់ជាងនេះទៅទៀត យើងសង្ឃឹមថាវិធានការ ដែលបានស្នើឡើងនេះ នឹងត្រូវបានដាក់បញ្ចូលទៅក្នុងគោលនយោបាយផ្លូវការរបស់គណបក្សដែលប្រកួតប្រជែង ហើយនឹងក្លាយជាសារដ៏សំខាន់ចាប់ពីពេលនេះ រហូតដល់យុទ្ធនាការបោះឆ្នោតនាពេលខាងមុខ»។

សេចក្តីស្នើគោលនយោបាយប្រឆាំងអំពើពុករលួយសម្រាប់ដាក់ជូនគណបក្សនយោបាយនេះ បានពិចារណា ទៅលើបីកម្រិតគឺ៖ កម្រិតបទដ្ឋាន កម្រិតស្ថាប័ន និងកម្រិតសហគមន៍។

*កម្រិតបទដ្ឋាន* បានផ្តោតលើសារៈសំខាន់នៃការអនុម័តច្បាប់មួយចំនួន ដែលចាំបាច់ក្នុងការទប់ស្កាត់ ការរាយការណ៍ និងការបង្ក្រាបអំពើពុករលួយ។ ក្នុងកម្រិតនេះយើងបានពិភាក្សាលើច្បាប់ចំនួនបីគឺ ច្បាប់ប្រឆាំងអំពើពុករលួយដែលមានស្រាប់ ច្បាប់ស្តីពីសិទ្ធិទទួលព័តមាន(កំពុងតាក់តែង) និងច្បាប់ការពារសាក្សី និងអ្នករាយការណ៍(កំពុងតាក់តែង)។

*កម្រិតស្ថាប័ន* ផ្តោតទៅលើសមត្ថភាពរបស់ស្ថាប័នអនុវត្តច្បាប់ ដែលរួមមានសមត្ថភាពនិងធនធានចាំបាច់ក្នុងការអនុវត្តច្បាប់ឲ្យមានប្រសិទ្ធិភាព។

*កម្រិតសហគមន៍* ផ្តោតទៅលើសារៈសំខាន់នៃការយល់ឃើញរបស់ប្រជាពលរដ្ឋ ក៏ដូចជាកម្រិតនៃការចូលរួមពីសហគមន៍នានា (សហគមន៍នយោបាយ សហគមន៍អាជីវកម្ម អង្គការសង្គមស៊ីវិល ។ល។ )

**មានភ្ជាប់មកជាមួយនូវសេចក្តីស្នើគោលនយោបាយប្រឆាំងអំពើពុករលួយ។**

**ទំនាក់ទំនងសំភាសន៍៖ លោក ព្រាប កុល នាយកប្រតិបត្តិ អង្គការតម្លាភាពកម្ពុជា**
**ទូរស័ព្ទ** 012 877 833, **អ៊ីម៉ែល** kolpreap@ticambodia.org

###

*Transparency International is the civil society organisation leading the fight against corruption*